**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
លេខ : ......១២....ប.ទ...សាផ៣......

# សេចក្តីជូនដំណឹង
# ស្តីពី
# ការពង្រឹងសណ្តាប់ធ្នាប់និងរបៀបរៀបរយក្នុងវិស័យទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមជូនដំណឹងដល់ប្រតិបត្តិករទូរគមនាគមន៍និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា គិតត្រឹមខែមីនា ឆ្នាំ២០២១ នេះ ប្រតិបត្តិករដែលបានទទួលអាជ្ញាបណ្ណផ្តល់សេវាទូរគមនាគមន៍មានចំនួន៤៩ ដូចមានក្នុងបញ្ជីជូនភ្ជាប់មកជាមួយ។

ដើម្បីរៀបចំវិស័យទូរគមនាគមន៍ឱ្យមានសណ្តាប់ធ្នាប់និងរបៀបរៀបរយ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានចាត់វិធានការលើប្រតិបត្តិករទូរគមនាគមន៍ដែលមិនអនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងក្រុមហ៊ុនដែលធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ ជាបន្តបន្ទាប់។ បន្ថែមពីនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមអំពាវនាវដូចខាងក្រោម៖

- ប្រតិបត្តិករទូរគមនាគមន៍មិនត្រូវសហការនិងលក់ដុំសេវាអ៊ីនធឺណិតដល់ក្រុមហ៊ុនដែលគ្មានអាជ្ញាបណ្ណដើម្បីចែកចាយសេវាអ៊ីនធឺណិតបន្តដល់អតិថិជនចុងក្រោយ
- សាធារណជនត្រូវបញ្ឈប់ការប្រើប្រាស់សេវាអ៊ីនធឺណិតដែលផ្តល់ដោយក្រុមហ៊ុនដែលគ្មានអាជ្ញាបណ្ណ។

ដើម្បីទទួលបានព័ត៌មានច្បាស់ថា ប្រតិបត្តិករទូរគមនាគមន៍ដែលជាដៃគូ ធ្វើអាជីវកម្មស្របច្បាប់ សូមប្រតិបត្តិករនិងសាធារណជនទាំងអស់ ពិនិត្យនិងផ្ទៀងផ្ទាត់បញ្ជីបច្ចុប្បន្នភាពឈ្មោះប្រតិបត្តិករដែលមានអាជ្ញាបណ្ណតាមរយៈគេហទំព័ររបស់និយ័តករទូរគមនាគមន៍កម្ពុជា ដែលមានអាសយដ្ឋាន **www.trc.gov.kh**។ ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍និងសាធារណជនមានព័ត៌មានអំពីក្រុមហ៊ុនធ្វើអាជីវកម្មផ្តល់សេវាអ៊ីនធឺណិតខុសច្បាប់ សូមមេត្តាផ្តល់ព័ត៌មានមកនិយ័តករទូរគមនាគមន៍កម្ពុជា តាមរយៈលេខទូរសព្ទ ០១២ ៧៣៣ ៣៥០ ឬ ០១៧ ៥០៥ ១៩១។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងចាត់វិធានការតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងករណីរកឃើញថា ប្រតិបត្តិករទូរគមនាគមន៍នៅតែបន្តសហការនិងផ្តល់សេវាលក់ដុំដល់ក្រុមហ៊ុនដែលគ្មានអាជ្ញាបណ្ណ។

អាស្រ័យហេតុនេះ សូមប្រតិបត្តិករទូរគមនាគមន៍និងសាធារណជនទាំងអស់ ជ្រាបនិងចូលរួមសហការប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ជា វ៉ាន់ដេត**

អាសយដ្ឋាន : អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ : www.mptc.gov.kh
ទូរសព្ទ : (៨៥៥) ២៣ ៧២៤ ៨១០
ទូរសារ : (៨៥៥) ២៣ ៧២៤ ០៦៩
អ៊ីមែល : info@mptc.gov.kh

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF POST
AND TELECOMMUNICATIONS
№: ..12. MPTC......

*[Unofficial Translation]*

# Announcement
# on
# The Enhancement of Order in the Telecommunications Sector

The Ministry of Post and Telecommunications (MPTC) would like to inform telecommunications operators and the public that as of March 2021, 49 telecommunications operators have been granted telecommunications licenses as in the attached list.

In order to organize the telecommunications sector, MPTC have taken measures against telecommunications operators who previously failed to comply with laws and regulations and against the unlicensed businesses. Additionally, MPTC would like to call on as follows:

- Telecommunications operators must not cooperate with and sell wholesale internet to unlicensed firms to distribute retail internet service to end users.
- The public must stop using the internet service provided by the unlicensed firms.

In order to obtain accurate information as to ascertain whether or not partner telecommunications operator(s) is legally licensed, all operators and the public may check and verify the names of licensed operators in the up-to-date list on Telecommunication Regulator of Cambodia (TRC) website, www.trc.gov.kh. In case telecommunications operators and the public are aware of any businesses providing illegal internet service, please inform TRC at 012 733 350 or 017 505 191.

MPTC will take actions in accordance with laws and regulations if MPTC finds that telecommunications operators remain cooperating with and selling wholesale internet to unlicensed businesses.

In this regard, telecommunications operators and the public should be informed and cooperate with the sense of responsibility.

Phnom Penh, 04 March 2021

*[Signed and Stamped]*

**Vandeth Chea**
Minister

Address: Building № 13, Preah Monivong Boulevard,
Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia
Website : www.mptc.gov.kh

Tel : (855) 23 724 810
Fax : (855) 23 724 069
Email : info@mptc.gov.kh